**NATIONS UNIES**
**HAUT COMMISSARIAT DES NATIONS UNIES**
**AUX DROITS DE L'HOMME**

**PROCEDURES SPECIALES ASSUMÉES PAR**
**LE CONSEIL DES DROITS DE L'HOMME**

**UNITED NATIONS**
**OFFICE OF THE UNITED NATIONS**
**HIGH COMMISSIONER FOR HUMAN RIGHTS**

**SPECIAL PROCEDURES ASSUMED BY THE**
**HUMAN RIGHTS COUNCIL**

**Mandates of the Special Representative of the Secretary-General for human rights in Cambodia and the Special Rapporteur on the independence of judges and lawyers**

Téléfax: (41-22)-917 90 06
Télégrammes:UNATIONS, GENEVE
Téléx: 41 29 62
Téléphone: (41-22)-917 92 55
Internet www.ohchr.org

Address:
Palais des Nations
CH-1211 GENEVE 10

*សេចក្តីថ្លែងការណ៍ជាសាធារណៈ*

# តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងអ្នករាយការណ៍ពិសេស ស្តីពីឯករាជ្យភាពចៅក្រម និងមេធាវី សំដែងកង្វល់អំពីឯករាជ្យភាពនៃចៅក្រមនៅកម្ពុជា ចំពោះការតែងតាំងចៅក្រមនាពេលថ្មីៗនេះ

*អង្គការសហប្រជាជាតិ, ២៣ សីហា ២០០៧*

លោកតំណាងពិសេស និងអ្នករាយការណ៍ពិសេស មានកង្វល់ថា ការតែងតាំងចៅក្រមនាពេលថ្មីៗនេះ ទំនងជាមិនបានធ្វើស្របតាមរដ្ឋធម្មនុញ្ញទេ ដែលនាំឱ្យមានចំងល់ថាតើគោលការណ៍ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញស្តីពីឯករាជ្យនៃអំណាចតុលាការ ត្រូវបានគោរពយ៉ាងពេញលេញ ឬទេនៅកម្ពុជា ។

បើតាមច្បាប់កម្ពុជា រាល់ការតែងតាំង ការផ្លាស់ប្តូរ ការតម្លើងសក្តិ ការដាក់ឱ្យនៅទំនេរ ឬការដាក់វិន័យចៅក្រម ត្រូវសំរេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈព្រះរាជក្រឹត្យ ។ ប៉ុន្តែព្រះរាជក្រឹត្យលេខ (NS/RKT/0807/339) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧ ដែលតែងតាំងចៅក្រម ជំនួសតំណែងប្រធានសាលាឧទ្ធរណ៍ ទំនងជាមិនបានធ្វើដោយផ្អែកតាមសេចក្តីសំរេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ : មិនមានការកោះប្រជុំឧត្តមប្រឹក្សានៃអង្គចៅក្រម មុននឹងចេញព្រះរាជក្រឹត្យនេះឡើយ ។

ជំនួសវិញ ព្រះរាជក្រឹត្យបញ្ជាក់ថា តាមការស្នើសុំពីប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ បន្ទាប់ពីមានការស្នើសុំពីសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ម្យ៉ាងវិញទៀត ការតែងតាំងជំនួសប្រធានសាលាឧទ្ធរណ៍ ធ្វើឡើងតាមការស្នើសុំរបស់ស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋាភិបាល ដោយផ្ទុយនឹងគោលការណ៍បែងចែកអំណាចតុលាការ និងអំណាចនីតិប្រតិបត្តិ ដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ ។

ដោយគ្មានការបញ្ជាក់ដល់អង្គសេចក្តីលើការចោទប្រកាន់ប្រធានសាលាឧទ្ធរណ៍ដែលត្រូវបានដកពីមុខតំណែង វិធានការដាក់វិន័យលើចៅក្រម បើតាមច្បាប់ គឺជាបុព្វសិទ្ធិរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើឡើងតាមរយៈក្រុមប្រឹក្សាវិន័យ ។ គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ ដែលបង្កើតបានជាផ្នែកមួយ នៃច្បាប់កម្ពុជាចែងថា ចៅក្រមដូចជាពលរដ្ឋដទៃទៀតដែរ មានសិទ្ធិទទួលបានការជំនុំជំរះប្រកបដោយយុត្តិធម៌ និងការធានាដទៃទៀតនៃនីតិវិធីត្រឹមត្រូវ ។ អំណាចនីតិប្រតិបត្តិគ្មានតួនាទីក្នុងការសំរេចថា ចៅក្រមណាម្នាក់ប្រព្រឹត្តមិនត្រឹមត្រូវ ហើយគួរដកហូតពីមុខតំណែងនោះទេ ។

ការតែងតាំងសមាជិកថ្មីបួនរូប នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយព្រះរាជក្រឹត្យមួយទៀតលេខ (NS/RKT/0807/340) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧ ទំនងជាបានធ្វើឡើងស្រដៀងគ្នានេះ តាមសំណើររបស់ស្ថាប័ននីតិប្រតិបត្តិ ជាជាងការធ្វើទៅតាមច្បាប់ ។

លោកតំណាងពិសេសបានសំដែងកង្វល់រួចមកហើយថា សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានរដ្ឋមន្ត្រីមួយរូប និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សកាន់អំណាច មិនបានធ្វើឱ្យមានការជឿជាក់ថា កិច្ចដំណើរតែងតាំងចៅក្រមនៅកម្ពុជា គ្មានការត្រួតត្រាខាងនយោបាយនោះឡើយ ។ ប៉ុន្តែព្រះរាជក្រឹត្យដែលបានចេញនាពេលថ្មីៗនេះ ពិតជាដាក់ឧត្តមប្រឹក្សានៃអង្គចៅក្រមនៅម្ខាង ដោយទុកតែតួនាទីអនុវត្តន៏សេចក្តីសំរេចមួយជាមួយនឹងឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលខ្លួនមិនទាំងបានអនុម័តយល់ព្រមជាផ្លូវការផងនោះ ។

ការតែងតាំងចៅក្រមបីរូបក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរាប់មុខតំណែងដែលបើតាមច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺបំរុងសំរាប់សមាជិកដែលត្រូវបោះឆ្នោតដោយចៅក្រម ។ មិនមានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងសំរាប់មុខតំណែងទាំងនេះទេតាមពិតទៅមិនមានការបោះឆ្នោតសំរាប់មុខតំណែងទាំងបីនេះទេ ។

ចៅក្រមឯករាជ្យមួយរូប គឺជាអ្នកធានាដ៏សំខាន់ចំពោះការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ ៖ បើគ្មានចៅក្រមឯករាជ្យទេនោះ គេមិនអាចធានាសិទ្ធិជនគ្រប់រូបក្នុងការជំនុំជំរះប្រកបដោយយុត្តិធម៌បានឡើយ ។ ប្រសិនបើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅតែត្រូវបានគេឃើញថា ស្ថិតក្រោមការត្រួតត្រារបស់រដ្ឋាភិបាលនោះ តុលាការកម្ពុជាមិនអាចត្រូវបានគេទទួលស្គាល់ថាឯករាជ្យឡើយ ។ ហើយប្រសិនបើតុលាការមិនឯករាជ្យ និងលំអៀង គេមិនអាចគ្រប់គ្រងប្រព័ន្ធយុត្តិធម៌បានត្រឹមត្រូវ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិឡើយ ។

លោកតំណាងពិសេស និងអ្នករាយការណ៍ពិសេស សូមអំពាវនាវដល់អាជ្ញាធរកម្ពុជា ឱ្យធានាការគោរពបទបញ្ញត្តិរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏ដូចជាច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា ដើម្បីអាចធានាបាននូវឯករាជ្យភាពនៃចៅក្រមកម្ពុជា ។

លោកក៏ចូលរួមជាមួយកង្វល់ដែលសំដែងរួចហើយ ដោយអង្គការសហប្រជាជាតិអំពីផលប៉ះពាល់នៃការផ្លាស់ប្តូរមុខតំណាងរបស់សហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ទៅកាន់មុខតំណែងជាប្រធានសាលាឧទ្ធរណ៍។ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសារសំខាន់ណាស់សំរាប់ការអភិវឌ្ឍន៍កម្ពុជា នៅថ្ងៃអនាគត ប៉ុន្តែគេមិនគួរធ្វើដោយមិនផ្តល់ការការពារចាំបាច់ដល់ចៅក្រម រួមទាំងការធានារយៈពេលកាន់មុខតំណែងដែលអាចឱ្យចៅក្រមគ្រប់គ្រង ហើយត្រូវគេឃើញថាបានគ្រប់គ្រងប្រព័ន្ធយុត្តិធម៌មានប្រសិទ្ធិភាព មិនលំអៀង និងត្រឹមត្រូវ ដោយគ្មានការជ្រៀតជ្រែកខាងនយោបាយ។

[ចប់ ]

## មូលដ្ឋានព័ត៌មាន

**តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា** គឺជាអ្នកជំនាញការឯករាជ្យ ប្រទានអាណត្តិដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិអោយតាមដានអង្កេតមើលនិងរាយការណ៍ពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ អាណត្តិរបស់លោកតំណាងពិសេស មានប្រភពដើមមកពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងមហាសន្និបាតអង្គការសហប្រជាជាតិ។ អ្នកកាន់អាណត្តិនេះសព្វថ្ងៃ គឺលោក **យ៉ាស្ស ហ្គាយ** ដែលបានទទួលអាណត្តិនេះ តាំងពីខែវិច្ឆិកា ឆ្នាំ២០០៥។ លោកសាស្ត្រាចារ្យ **ហ្គាយ** គឺជាបណ្ឌិតសភា និងជាអ្នកច្បាប់រដ្ឋធម្មនុញ្ញ មកពីប្រទេសកេនយ៉ា។

**អ្នករាយការណ៍ពិសេសពីឯករាជ្យភាពចៅក្រម និងមេធាវី** គឺជាអ្នកជំនាញការឯករាជ្យ ប្រទានអាណត្តិដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អោយតាមដានអង្កេតមើលការវាយប្រហារលើឯករាជ្យភាពតុលាការ មេធាវី និងមន្ត្រីតុលាការ និងធ្វើអោយបានសំរេចក្នុងការការពារ និងលើកកំពស់ឯករាជ្យភាពរបស់ពួកគេ។ អ្នកកាន់អាណត្តិនេះសព្វថ្ងៃ គឺលោក **លៀនអេនឌ្រូ ដេសព្វយ** ដែលបានទទួលអាណត្តិនេះ តាំងពីខែសីហា ឆ្នាំ២០០៣។ **លោក ដេសព្វយ** គឺជាបណ្ឌិតសភា និងជាអ្នកច្បាប់សិទ្ធិមនុស្ស មកពីប្រទេសអាហ្សង់ទីន។

## ច្បាប់កម្ពុជាដែលពាក់ព័ន្ធ

មាត្រា១២៨នៃរដ្ឋធម្មនុញ្ញ បង្កើតតុលាការ ថាជាអ្នកការពារដែលមានឯករាជ្យ និងមិនលំអៀងដល់សិទ្ធិមនុស្ស និងសេរីភាពរបស់ប្រជាពលរដ្ឋ។ មាត្រា១៣០ចែងថា "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ។" មាត្រា១៣៣គូសបញ្ជាក់ថា "ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស។" មាត្រា១៣២ប្រទានអំណាចដល់ព្រះមហាក្សត្រ ថាទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ដែលតាមរយៈមាត្រា១៣៤ ឧត្តមក្រុមប្រឹក្សានេះមានអំណាចពិសេស ក្នុងការលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់។

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ១៩៩៤ តម្រូវថា រាល់ការតែងតាំង ការផ្លាស់ប្តូរ ការតំលើងស័ក្តិ ការដាក់អោយនៅទំនេរ ឬវិធានការវិន័យផ្សេងទៀត ត្រូវសំរេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈព្រះរាជក្រិត្យ (មាត្រា១១) ។ មាត្រា១២ និងមាត្រាបន្តបន្ទាប់មកទៀត ចែងពីការបង្កើតក្រុមប្រឹក្សាវិន័យ ដើម្បីសំរេចពីវិធានការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា។ មាត្រា២ កំណត់ពីសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរួមមានសមាជិក៦រូបដែលបានក្លាយជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយសារតែស្ថិតក្នុងតំណែង (ព្រះមហាក្សត្រ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចាងហ្វាងសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍) ។ សមាជិកដែលនៅសល់បីរូបទៀត គឺជាចៅក្រមដែលត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយចៅក្រម ។ ការបោះឆ្នោតត្រូវរៀបចំឡើងអោយស្របតាមមាត្រា៦ និងមាត្រា២១ ហើយត្រូវធ្វើក្រោយពីច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមចូលជាធរមាន ។ ក្នុងរយៈពេល១៣ឆ្នាំកន្លងមកនេះ តាំងពីច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានអនុម័តមក គ្មានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ត្រូវបានអនុម័តឡើយ ។

## លិខិតុបករណ៍អន្តរជាតិដែលទាក់ទងនឹងឯករាជ្យភាពតុលាការ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលធានាការពារដោយមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ចែងថា "មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំអោយតុលាការឯករាជ្យនិងមិនលំអៀងមួយ ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយត្រឹមត្រូវ ក្នុងការសំរេចពីសិទ្ធិ កាតព្វកិច្ច និងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយចំពោះរូបគេ។ " (មាត្រា១០)

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីតាំងពីឆ្នាំ១៩៩២ ហើយដែលធានាការពារដោយមាត្រា៣១នៃរដ្ឋធម្មនុញ្ញ ចែងថា " ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានសវនាការមួយត្រឹមត្រូវ និងជាសាធារណៈដោយតុលាការមួយមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ហើយដែលបង្កើតឡើងដោយច្បាប់ ។ " (មាត្រា១៤)

គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការដែលត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា មានចែងដូចខាងក្រោមនេះ:

១- រដ្ឋត្រូវធានានូវឯករាជ្យភាពរបស់តុលាការ ហើយឯករាជ្យភាពនេះត្រូវតែតំកល់នៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ជាតិ។ នេះគឺជាកាតព្វកិច្ចរបស់ស្ថាប័នរដ្ឋ និងស្ថាប័នដទៃទៀតទាំងអស់ ក្នុងការគោរព និងប្រតិបត្តិតាមឯករាជ្យភាពរបស់តុលាការ...។

៤- មិនត្រូវឱ្យមានការជ្រៀតជ្រែកដែលមិនសមស្រប ឬគ្មានយុត្តិកម្មណាមួយ ទៅក្នុងកិច្ចការរបស់តុលាការឡើយ ហើយសេចក្តីសំរេចរបស់តុលាការ មិនត្រូវឱ្យមានការពិនិត្យសើរើវិញដែរ....។

៦- គោលការណ៍ឯករាជ្យភាពរបស់តុលាការ ផ្តល់អំណាច និងតម្រូវឱ្យតុលាការធានាថា ចំណាត់ការតាមផ្លូវច្បាប់ ត្រូវតែប្រព្រឹត្តទៅអោយបានត្រឹមត្រូវ ហើយត្រូវគោរពដល់សិទ្ធិរបស់គូភាគី។

៧- រដ្ឋសមាជិកនីមួយៗ មានកាតព្វកិច្ចផ្តល់ធនធានអោយបានគ្រប់គ្រាន់ ដើម្បីឱ្យតុលាការអាចបំពេញមុខងាររបស់ខ្លួនបានត្រឹមត្រូវ។

១០- បុគ្គលដែលត្រូវជ្រើសរើសឱ្យចូលបំរើការក្នុងតុលាការ ត្រូវតែជាបុគ្គលសុចរិតទៀងត្រង់ និងមានសមត្ថភាព ដោយមានការបណ្តុះបណ្តាលត្រឹមត្រូវ ឬមានលក្ខណៈសម្បត្តិខាងផ្នែកច្បាប់ ។ ការជ្រើសរើសចៅក្រម ទោះបីតាមវិធីណាក៏ដោយ ក៏ត្រូវតែការពារអោយផុតពីតាមការចាត់តាំងចៅក្រម ដោយមូលហេតុមិនសមរម្យ ។ ក្នុងការជ្រើសរើសចៅក្រម មិនត្រូវឱ្យមានការរើសអើងចំពោះបុគ្គលណាម្នាក់ដោយមូលហេតុ ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ ប្រភពកំណើត ឬឋានៈដទៃទៀត លើកលែងតែមានការតម្រូវឱ្យបេក្ខជនសំរាប់តុលាការនោះ ត្រូវតែមានសញ្ជាតិនៃប្រទេសសាមីនោះប៉ុណ្ណោះ ដែលមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

១១- អាណត្តិការងាររបស់ចៅក្រម ឯករាជ្យភាពរបស់គេ សន្តិសុខ ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ លក្ខខណ្ឌការងារ ប្រាក់សោធននិវត្តន៍ និងអាយុចូលនិវត្តន៍របស់ចៅក្រម ត្រូវតែធានាឱ្យបានគ្រប់គ្រាន់ដោយច្បាប់ ។

១២- ចៅក្រមគ្រប់រូប ទោះជាត្រូវតែងតាំង ឬត្រូវបោះឆ្នោតជ្រើសរើសក្តី ត្រូវបានធានាអោយកាន់មុខតំណែង រហូតដល់អាយុចូលនិវត្តន៍តាមច្បាប់កំណត់ ឬរហូតដល់ចប់អាណត្តិនៃសាលាក្តីនោះ បើសិនជាសាលាក្តីនោះអាច កើតមានឡើង ។

១៣- ប្រសិនជាមានការតំលើងឋានន្តរសក្តិដល់ចៅក្រម គួរផ្អែកលើកត្តាសត្យានុម័ត ជាពិសេសសមត្ថភាព ភាពសុចរិតទៀងត្រង់ និងបទពិសោធន៍... ។

១៧- ការចោទប្រកាន់ ឬបណ្តឹងតវ៉ាទៅលើចៅក្រមណាមួយដែលកំពុងស្ថិតក្នុងមុខតំណែង និងកំពុងប្រកប វិជ្ជាជីវៈ ត្រូវតែចាត់ការដោះស្រាយឱ្យបានរួសរាន់ និងដោយយុត្តិធម៌តាមនីតិវិធីដ៏ត្រឹមត្រូវមួយ ។ ចៅក្រមត្រូវមានសិទ្ធិទទួលបាន ការជំនុំជំរះដ៏ត្រឹមត្រូវមួយ ។ ការសួរដេញដោលលើរឿងក្តី ក្នុងដំណាក់កាលដំបូង ត្រូវរក្សាទុកជាការសំងាត់ វាលែងតែមានការស្នើសុំពីចៅក្រមរូបនេះ ។

១៨- គេអាចព្យួរ ឬដកចៅក្រមចេញពីមុខតំណែងបាន តែដោយសារមូលហេតុអសមត្ថភាព ឬអត្តចរិតមិនសក្តិសម សំរាប់ការបំពេញភារកិច្ចរបស់ខ្លួនជាចៅក្រមតែប៉ុណ្ណោះ ។

១៩- រាល់ចំណាត់ការដាក់វិន័យ ការព្យួរ ឬការដកចេញពីមុខតំណែង ត្រូវកំណត់ឱ្យស្របទៅតាមបទដ្ឋាននៃ ក្រមសីលធម៌ចៅក្រមដែលមានស្រាប់ ។

២០- សេចក្តីសំរេចក្នុងចំណាត់ការដាក់វិន័យ ការព្យួរ ឬការដកចៅក្រមចេញពីមុខតំណែង ត្រូវស្ថិតក្រោម ការពិនិត្យមើលឡើងវិញដោយឯករាជ្យមួយ ។ គោលការណ៍នេះមិនអាចអនុវត្តចំពោះសេចក្តីសំរេចរបស់តុលាការជាន់ខ្ពស់ និងសេចក្តីសំរេចរបស់ស្ថាប័ននីតិបញ្ញត្តិក្នុងការចោទប្រកាន់ ឬចំណាត់ការផ្សេងៗទៀតដែលស្រដៀងគ្នានេះទេ ។

នស/រកត/០៨០៧/៣៨០

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឈរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការតែងតាំង និងសកម្មភាពរបស់សាលាជំនុំជំរះក្ដី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ស្ថានភាពចាំបាច់ នៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់គោលការណ៍នៃសមត្ថកិច្ចជាប់ចំណង
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ប្រធានឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដោយផ្អែកតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងជាសមាជិកឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលមាននាមនាមដូចខាងក្រោម :

១-ឯកឧត្ដម **យូ ប៊ុនឡេង** ជំនួសលោកជំទាវ **លី វួចឡេង**

២-លោក **ជីវ កេង** ជំនួសលោក **អ៊ុំ សារិទ្ធ**

៣-លោក **ខៀវ សារម៉េត** ជំនួសលោក **ធី ណេង**

៤-លោក **ស៊ិន ឌីម** ជំនួសលោក **វៀល មួន** ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** : ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

៣៧.០៧០៨.៣៦៣

នរោត្ដម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៧

ដើម្បីចម្លងចែក

ឆ្នាំ២០០៧

រាជរដ្ឋាភិបាល

នស/រកត/០៨០៧/៣៣៩

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការតែងតាំង និងសកម្មភាពរបស់សាលាជំនុំជំរះក្តី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៥/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ស្ថានភាពចាំបាច់ នៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់គោលការណ៍នៃសមត្ថកិច្ចជាប់ចំណង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដោយផ្អែកតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ចប់តំណែងលោកជំទាវ ឈី ទូចឡេង ពីប្រធានសាលាឧទ្ធរណ៍ ឱ្យទៅបម្រើការងារនៅក្រសួងយុត្តិធម៌ ។

**មាត្រា២ :** ត្រូវបានតែងតាំងឯកឧត្តម យូ អ៊ុនឡេង បច្ចុប្បន្នចៅក្រមនៅសាលាឧទ្ធរណ៍ ជាប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៧០៨.៣៦២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៧

លេខ ... ច.ល
ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១០ ... ឆ្នាំ២០០៧
... រាជរដ្ឋាភិបាល

ឃុន ជិនកេន